# ខ្លឹមសារសង្ខេប
# ទស្សនៈរបស់គណៈកម្មាធិការសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (UNHRC)
# បណ្ដឹងលេខ១៣២០/២០០៤

**១.ពាក្យគន្លឹះ៖** សិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព, សិទ្ធិទទួលបានសំណង, រយៈពេលសមស្រប, ការអនុវត្តសាលក្រមបរទេសក្នុងស្រុក

**២. នីតិវិធី៖** អ្នកប្ដឹង មានចំនួនច្រើនរូប មានសញ្ជាតិហ្វីលីពីន។ គាត់ជាអតីតជនរងគ្រោះនៃបទឧក្រិដ្ឋដូចជាទារុណកម្ម ក្នុងឆ្នាំ ១៩៧៤ ក្នុងសម័យដឹកនាំរបស់លោក ម៉ាកកូស។ គាត់បានប្ដឹង ប្រឆាំងលោក ម៉ាកកូស ទៅតុលាការសហរដ្ឋអាមេរិក ដែលតុលាការនេះ ក្នុងឆ្នាំ ១៩៨៦ បានចេញសាលក្រមស្ថាពរ សម្រេចផ្ដល់សំណងជាច្រើនរយលានដុល្លាជូនពួកគាត់។ ដើម្បីទារសំណង ក្នុងឆ្នាំ ១៩៩៧ សមាជិកប្រាំក្រុម បានដាក់ពាក្យបណ្ដឹងទៅតុលាការតំបន់ក្នុងប្រទេសហ្វីលីពីន ក៏ប៉ុន្តែ ត្រូវបានបដិសេធ ដោយសារអ្នកប្ដឹងមិនបានបង់ប្រាក់ប្រដាប់ក្ដី (filing fee) ប្រហែល ៨.៤ លានដុល្លា។ អ្នកប្ដឹងអះអាងថា នីតិវិធីនៅមុខតុលាការក្នុងស្រុក យឺតយ៉ាវ ហើយការតម្រូវឲ្យបង់ប្រាក់ប្រដាប់ក្ដីនេះ វាដូចជា ការបដិសេធដោយប្រយោល (*de facto*) នូវសិទ្ធិទទួលបានដំណោះស្រាយ ក្នុងការទទួលបានសំណង ដែលនេះជាការបំពានមាត្រា២ នៃកតិកាសញ្ញា (កថាខ័ណ្ឌទី៣)។

ហ្វីលីពីន ជារដ្ឋភាគី មិនបានឆ្លើយតបលម្អិតទេ គ្រាន់តែអះអាងថា អ្នកប្ដឹង បានទទួលនូវដំណោះស្រាយមានប្រសិទ្ធភាពហើយ។ អ្នកតំណាងក្រុមសម្រាប់គោលបំណងប្ដឹង ផ្សេងពីអ្នកតំណាងក្រុមសម្រាប់ប្ដឹងទារសំណង ដែលត្រូវបង់តម្លៃប្រដាប់ក្ដីដោយឡែកៗផ្ទាល់ខ្លួន។ ការមិនធ្វើដូចនេះ នាំឲ្យពួកគាត់មិនមានសិទ្ធិប្ដឹងទារសំណងជំនួសទេ (no legal standing)។ ការខកខាន នាំឲ្យមានការបដិសេធ បណ្ដឹង និងបង្កជាភាពយឺតយ៉ាវ។

## ៣. សំអាងហេតុ និងសេចក្ដីសម្រេច

ចំពោះរយៈពេលនៃនីតិវិធី (បញ្ហាប្រាក់ប្រដាប់ក្ដី) តាមអង្គហេតុ តុលាការតំបន់ និងតុលាការកំពូល បានចំណាយពេល ៨ឆ្នាំ និងមិនបានពន្យល់អំពីមូលហេតុនៃការយឺតយ៉ាវ ទោះបីជា សំណុំរឿងនេះមិនសូវមានភាពស្មុគ្រស្មាញក្ដី។ នេះជាករណី យឺតយូរដោយមិនសមហេតុផល ដែលជាការបំពានមាត្រា ១៤(១) ពិចារណាជាមួយនឹងមាត្រា ២(៣) នៃកតិកាសញ្ញា។

### ៤. កំណត់សំគាល់ (ខ្លឹមសារល្អ សម្រាប់ដកស្រង់)

*គណៈកម្មាធិការ មានទស្សនៈថា អ្នកប្ដឹង តាមមាត្រា២(៣)នៃកតិកាសញ្ញា មានសិទ្ធិទទួលបានដំណោះស្រាយមានប្រសិទ្ធភាព។ រដ្ឋភាគី មានកាតព្វកិច្ចក្នុងការធានានូវដំណោះស្រាយគ្រប់គ្រាន់ចំពោះអ្នកប្ដឹង រាប់បញ្ចូលនូវ សំណង ដំណោះស្រាយឆាប់រហ័ស នៃសំណុំរឿងរបស់ពួកគេ ស្ដីពី ការអនុវត្តសាលក្រមតុលាការសហរដ្ឋអាមេរិកក្នុងរដ្ឋភាគី។ រដ្ឋភាគី មានកាតព្វកិច្ចក្នុងការធ្វើឲ្យប្រាកដប្រជាថា ការបំពានស្រដៀងនេះ នឹងមិនកើតមាននាពេលអនាគតទេ* (កថាខ័ណ្ឌទី១១)។

ទស្សនៈទាំងស្រុងសូមមើល៖ [CCPR/C/89/D/1320/2004, Communication No. 1320, Mariano v. the Philippines]